ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)




# គោលការណ៍ណែនាំស្តីពី
# របៀបផលិតឯកសារផ្សព្វផ្សាយកសិកម្ម


**រៀបចំដោយ ហួត ខៀវ**

**ទីប្រឹក្សាថ្នាក់ជាតិ សម្រាប់វគ្គបណ្តុះបណ្តាលស្តីពីការផលិតឯកសារផ្សព្វផ្សាយកសិកម្ម**



**រៀបចំដោយ:** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

**ឧបត្ថម្ភដោយ:** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

**ឧសភា ឆ្នាំ ២០១៧**

**ភ្នំពេញ, កម្ពុជា**

## មាតិកា

អក្សរកាត់ ........ 1
សង្ខេប ........ 2
គោលការណ៍ណែនាំស្តីពីរបៀបផលិតឯកសារផ្សព្វផ្សាយ ........ 3
១. កំណត់ វិភាគ និងចាត់អាទិភាពបញ្ហា ........ 3
១-១ កំណត់បញ្ហា ........ 3
១-២ វិភាគបញ្ហា ........ 4
១-៣ ចាត់អាទិភាពបញ្ហា ........ 4
២. រៀបចំពង្រាងឯកសារផ្សព្វផ្សាយ ........ 6
២-១ បង្កើតសាច់រឿង ........ 6
២-២ ជ្រើសរើសប្រភេទឯកសារផ្សព្វផ្សាយឱ្យសមស្រប ........ 8
២-៣ ជ្រើសរើសភាសាឱ្យសមស្រប ........ 14
២-៤ រៀបចំគំនូសប្លង់ព្រាងឯកសារ ........ 15
២-៥ រៀបចំឯកសារផ្តោតលើលំហូរព័ត៌មាន ........ 15
២-៦ រៀបចំឯកសារឱ្យទាក់ទាញខ្លាំង ........ 17
៣. វាយតម្លៃពង្រាងឯកសារ ........ 18
៣-១ ត្រួតពិនិត្យពង្រាងឯកសារ ........ 19
៣-២ តេស្តឯកសារ ........ 19
ឯកសារយោង ........ 21

# អក្សរកាត់

| | |
|---|---|
| ASPIRE | កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| CEWs | មន្ត្រីផ្សព្វផ្សាយថ្នាក់ឃុំ |
| DAE | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| DAO | មន្ត្រីកសិកម្មថ្នាក់ស្រុក |
| DSA | ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ |
| EMDs | មន្ត្រីអភិវឌ្ឍន៍សំភារៈផ្សព្វផ្សាយ |
| FA | ជំនួយការហិរញ្ញវត្ថុ |
| FMM | សៀវភៅគ្រប់គ្រងហិរញ្ញវត្ថុរបស់កម្មវិធីASPIRE |
| FNA | ការវាយតម្លៃតម្រូវការកសិករ |
| FO | មន្ត្រីហិរញ្ញវត្ថុ |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| KSA | ចំណេះដឹង ជំនាញ និងឥរិយាបថ |
| IFAD | ហិរញ្ញវត្ថុអន្តរជាតិ សំរាប់អភិវឌ្ឍន៍កសិកម្ម |
| M&E | ត្រួតពិនិត្យនិងវាយតម្លៃ |
| MC | អ្នកកាន់កាប់កម្មវិធី |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| OOW | មន្ត្រីចាត់ចែងរៀបចំសិក្ខាសាលា |
| QA | ធានាគុណភាពវាស់វែង |
| QCM | សំនួរជ្រើសរើស |
| PDAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| PIM | ផែនការអនុវត្តន៍គម្រោង |
| PM | ប្រធានគម្រោង |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| TNA | ប៉ាន់ប្រមាណតម្រូវការសម្រាប់បណ្តុះបណ្តាល |
| TWO | អ្នកចាត់ចែងវគ្គបណ្តុះបណ្តាល សិក្ខាសាលា |
| TOT | បណ្តុះបណ្តាលគ្រូបង្គោល |
| USAID | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិច |

# សង្ខេប

គោលការណ៍ណែនាំនេះនឹងណែនាំដល់មន្ត្រីជំនាញផ្សព្វផ្សាយកសិកម្មពីរបៀបផលិតឯកសារផ្សព្វផ្សាយកសិកម្មហើយនឹងជួយពួកគេអនុវត្តវគ្គបណ្តុះបណ្តាលបន្តដល់ភ្នាក់ងារផ្សព្វផ្សាយឃុំប្រកបដោយប្រសិទ្ធិភាពនិងប្រសិទ្ធិផល(មើលរូបភាពទី១)។  មានជំហានបីសំខាន់ដែលក្នុងនោះមានសកម្មភាពតូចៗដែលត្រូវអនុវត្តនិងរៀបរាប់នៅក្នុងឯកសារនេះ។




រូបភាព ១ ជំហានក្នុងការផលិតឯកសារផ្សព្វផ្សាយកសិកម្ម

នៅពេលដែលឯកសារផ្សព្វផ្សាយក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធិភាពសម្រាប់ការសិក្សានិងផ្លាស់ប្តូរពត៌មាន នោះវានឹងមានសារះសំខាន់សម្រាប់អ្នកផលិតឯកសារគួរយកចិត្តទុកដាក់ឲ្យបានច្រើន ហើយត្រូវប្រាកដថារាល់ការផលិតឯកសារផ្សព្វផ្សាយត្រូវគោរពទៅតាមគោលការណ៏សំខាន់ទាំង៥ ដូចរ៉ាយរាប់ដូចខាងក្រោមៈ

- ឆ្លើយតបនឹងគោលនយោបាយផ្សព្វផ្សាយកសិកម្មរបស់ក្រសួង
- ឆ្លើយតបនឹងក្រុមគោលដៅ និងបញ្ហារបស់ពួកគេ( ឧ. ក្រុមជនក្រីក្រ និងស្ត្រី។ល។)
- គួរជ្រើសរើសវិធីសាស្ត្រផ្សព្វផ្សាយ និងខ្លឹមសារស្នូលឲ្យបានសមស្រប
- គួរវាយតម្លៃឯកសារផ្សព្វផ្សាយមុននឹងយកមកអនុវត្ត
- គួរពិចារណាលើសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធ(មានន័យថា សមត្ថភាពមន្ត្រី ផែនការ និងថវិកា)។

លើសពីនេះទៀត ដំណើរការផលិតឯកសារផ្សព្វផ្សាយកសិកម្មគួរតែមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ ដូចជា ជាមួយកសិករ ភ្នាក់ងារផ្សព្វផ្សាយ មន្ត្រីគម្រោង និងអ្នកវិទ្យាសាស្ត្រជាដើម។ ហេតុដូចនេះ

ដើម្បីពង្រីកវិសាលភាពលទ្ធផលរបស់កម្មវិធីគួរផ្តោតនូវគោលការណ៍សំខាន់ៗ(មើលរូបភាពទី២)។




រូបភាព ២ គោលការណ៍ដែលធ្វើឲ្យមានវិសាលភាពនៃការអនុវត្ត

# គោលការណ៍ណែនាំស្តីពីរបៀបផលិតឯកសារផ្សព្វផ្សាយ

គោលការណ៍ណែនាំនេះរ៉ាយរាប់ពីទស្សនទាន ដំណើរការ និងតិចនិចក្នុងការផលិតឯកសារផ្សព្វផ្សាយ ជាជាងការឃ្លាំមើលការប្រើប្រាស់ឯកសារ។

ខាងក្រោមជាគោលការណ៍ណែនាំនានាដែលមន្ត្រីផលិតឯកសារផ្សព្វផ្សាយគួរអនុវត្តឲ្យបានហ្មត់ចត់នៅពេលដែលពួកគេផលិតឯកសារផ្សព្វផ្សាយ និងធ្វើការបណ្តុះបណ្តាលបន្តទៅអ្នកដទៃ។

# ១. កំណត់ វិភាគ និងចាត់អាទិភាពបញ្ហា

នៅក្នុងផ្នែកនេះមានសកម្មភាពធំបីគួរអនុវត្ត ១)កំណត់បញ្ហា ២) វិភាគបញ្ហា និង ក្រុមគោលដៅ និង ៣)ចាត់អាទិភាពបញ្ហា។

## ១-១ កំណត់បញ្ហា

ដើម្បីកំណត់បញ្ហាគួរយកចិត្តទុកដាក់លើសកម្មភាព៣សំខាន់:

- រៀបចំសំនួរដែលផ្តោតលើ:១)ក្រុមគោលដៅ ២)ឬសគល់បញ្ហា និង ៣)តម្រូវការ។
- ជ្រើសរើសវិធីសមស្របក្នុងការប្រមូលទិន្នន័យ( ឧ-តាមរយៈក្រុមពិភាក្សាមិនផ្លូវការ ចុះអង្កេតជាមួយក្រុមគោលដៅ ពិភាក្សាក្រុម សង្កេត កសិករ)និង
- ប្រមូលនិងចងក្រងទិន្នន័យដើម្បីវិភាគ។

## ១-២ វិភាគបញ្ហា

មានការវិភាគ២ប្រភេទសំខាន់និងចាំបាច់:១) វិភាគក្រុមគោលដៅ និង២)វិភាគឬសគល់បញ្ហារបស់ពួកគេ។ អាចធ្វើការវិភាគក្រុមគោលដៅជាទម្រង់បុគ្គលម្នាក់ៗ និង រឺជាក្រុមហើយសំណួរគួរផ្តោតលើ:

- ចំណាប់អារម្មណ៍ឬ តម្រូវការរបស់ពួកគេ
- ឥទ្ធិពលរបស់ពួកគេលើគម្រោង
- ចំណេះដឹងនិងបទពិសោធន៍របស់ពួកគេ
- វិភាគទានរបស់ពួកគេដល់ភាពជោគជ័យនៃគម្រោង
- កត្តាអសកម្មនិងបរាជ័យនៃគម្រោង
- កត្តាដែលជំរុញឲ្យក្រុមគោលដៅធ្វើសេចក្តីសម្រេចចិត្ត ផែនការ និងអនុវត្ត។ល។

ការវិភាគឬសគល់បញ្ហានិងតម្រូវការរបស់ពួកគេអាចធ្វើបានតាមរយៈវិធីសាស្ត្រផ្សេងៗដូចជា: វិធីវិភាគតាមរបៀបឆ្អឹងត្រី (fish borne) វិធីវិភាគតាមរបៀបដើមឈើ (problems tree) និង វិធីវិភាគតាមរបៀបដ្យាក្រាម (diagram analysis)។ល។

## ១-៣ ចាត់អាទិភាពបញ្ហា

ការចាត់អាទិភាពបញ្ហានិងតម្រូវការគឺអាស្រ័យលើគោលនយោបាយ កម្មវត្ថុរបស់កម្មវិធី និងសមត្ថភាពស្ថាប័នក្នុងការអនុវត្តកម្មវិធី និងការផ្តល់សេវាព្រមទាំងលទ្ធផលវិភាគក្រុមគោលដៅខាងលើ។ ខាងក្រោមជាឧទាហរណ៍នៃបញ្ហា។

- ការប្រើថ្នាំកំចាត់សត្វល្អិតលើស្រូវមិនសមស្រប
- ឱនភាពជីវជាតិដី
- ការប្រើបច្ចេកទេសថ្មីក្នុងការចិញ្ចឹមជ្រូកមិនសមស្រប
- ខ្វះបច្ចេកទេសចិញ្ចឹមត្រីដោយប្រើចំណីតិច
- ការជ្រើសរើសគ្រាប់ពូជស្រូវដែលអាចសម្របនឹងប្រែប្រួលអាកាសធាតុនៅមានកម្រិត
- ខ្វះបច្ចេកទេសដាំស្រូវឲ្យទទួលផលបានផលច្រើន។

មធ្យោបាយដ៏ងាយស្រួលក្នុងការចាត់អាទិភាពបញ្ហាគឺគួរស្នើឲ្យបុគ្គលម្នាក់ៗដាក់ពិន្ទុលើបញ្ហាបញ្ហានីមួយៗ រួចធ្វើចំណាត់ថ្នាក់ដោយគិតជាមធ្យមភាគសម្រាប់ក្រុមកសិករ (មើលឧទាហរណ៍ខាងក្រោម)។ កត់សំគាល់ថា ពិន្ទុខ្ពស់គឺជាបញ្ហាសំខាន់ត្រូវយកចិត្តទុកដាក់និងដោះស្រាយដំបូង។ តែពេលខ្លះ បញ្ហាជំរើសទី២ក៏អាចចាត់ជាអាទិភាពនិងត្រូវអនុវត្តដំបូងដែរ ដោយសារមានកត្តាមួយចំនួនដូចជា: ភាពងាយស្រួលអនុវត្ត អាចទទួលផលបានរហ័ស និង ត្រូវការធនធានតិច។ល។ គួរកត់សំគាល់ថាបញ្ហាគួរកំណត់ដោយកសិករជាជាងអ្នក

ធ្វើសេចក្តីសម្រេចចិត្តនិងរីអ្នកធ្វើផែនការ។ ទោះបីយ៉ាងណា រាល់សេចក្តីសម្រេចចិត្តណាមួយគួរមានការពិនិត្យនិងយល់ព្រមពីសហគមន៍ ទោះបីអ្នកនយោបាយនិងអ្នកធ្វើផែនការមានចំណេះពីសហគមន៍និងធនធានក៏ដោយ។

| ចំណាត់ថ្នាក់តាមបុគ្គល | ចាត់អទិភាពបញ្ហា | ចំណាត់ថ្នាក់តាមក្រុម |
|---|---|---|
| | ការប្រើថ្នាំកំចាត់សត្វល្អិតលើស្រូវមិនបានសមស្រប | |
| | ការថយចុះជីវជាតិដី | |
| | ការប្រើបច្ចេកទេសថ្មីក្នុងការចិញ្ចឹមជ្រូកមិនបានសមស្រប | |
| | ខ្វះបច្ចេកទេសចិញ្ចឹមត្រីដោយប្រើចំណីតិច | |
| | ការជ្រើសរើសគ្រាប់ពូជស្រូវដែលសម្របនឹងប្រែប្រួលអាកាសធាតុនៅមានកម្រិត | |
| | ខ្វះបច្ចេកទេសទទួលផលស្រូវច្រើន | |

ក្រោយពីការចាត់អាទិភាពរួច គួរកំណត់កម្មវត្ថុអនុវត្តឲ្យឆ្លើយតបនឹងឬសគល់បញ្ហានិងតម្រូវការរបស់កសិករ ហើយគួររៀបរាប់ពីចំណេះដឹង(ដូចជា ការផ្តល់ពត៌មាន គំនិត និងហេតុការណ៍)ជំនាញនិងឥរិយាបថដើម្បីសិក្សានិងផ្លាស់ប្តូរក្រុមគោលដៅដែលចង់ទទួលនៅពេលបញ្ចប់វគ្គបណ្តុះបណ្តាលឬកម្មវិធី។លើសពីនេះកម្មវត្ថុគួរSMART។

S: ធ្វើឱ្យជឿជាក់(មានន័យថាកំណត់បញ្ហាឱ្យចំនឹងតម្រូវការ)។

M: អាចវាស់វែងបាន(មានន័យថាបង្ហាញនូវលទ្ធផលយ៉ាងហោចណាស់ឆ្លុះបញ្ចាំងនូវការរីកចម្រើន)។

A: អាចទទួលផលបាន(មានន័យថាលទ្ធផលអាចទទួលបានក្នុងរយៈពេលខ្លី និងយូរ)។

R: អាចជឿទុកចិត្តបាន(មានន័យថាលទ្ធផលអាចទទួលបានប្រកបដោយជឿជាក់ទៅតាមធនធានដែលមាន)។

T: ពេលសមស្រប (មានន័យថា កំណត់ពេលជាក់លាក់ដែលលទ្ធផលអាចទទួលបាន)។

គួរចងចាំថា ដើម្បីឲ្យកម្មវត្ថុSMART គួរជ្រើសរើសកិរិយាស័ព្ទណាដែលជាក់លាក់ដូចរៀបរាប់នៅតារាងទី១ខាងក្រោម។ គួរកត់សំគាល់ថាមានកិរិយាស័ព្ទល្អៗជាច្រើនដែលអាចដកស្រង់ចេញពីឯកសារបង្រៀនដែលរៀបចំដោយ បណ្ឌិត ម៉ាក់ សឿន និង លោក សាយ តុម។

| កិរិយាស័ព្ទទូទៅ | កិរិយាស័ព្ទជាក់លាក់ |
|---|---|
| – ស្វែងយល់<br>– ស្គាល់<br>– ទទួលស្គាល់ | – តារាងបញ្ជី<br>– កំណត់<br>– អនុវត្តបង្ហាញ<br>– ជ្រើសរើស |

| | |
|---|---|
| | – អនុវត្តជាក់ស្តែង<br>– កំណត់ន័យ<br>– អនុវត្តការងារ<br>– យកចិត្តទុកដាក់<br>– ពិភាក្សា<br>– រៀបរាប់។ល។ |

តារាង ១ កិរិយាស័ព្ទជាក់លាក់

លើសពីនេះ កម្មវត្ថុគួរឆ្លើយនឹងសំណួរដូចខាងក្រោម៖

- ធ្វើរយៈពេលប៉ុន្មាន?
- ធ្វើជាមួយនរណា មានប៉ុន្មាននាក់?
- ធ្វើដើម្បីអ្វី(មូលហេតុដែលយើងបង្កើតកម្មវត្ថុនេះ)?

<u>ឧទាហរណ៍</u>

ក) នៅចុងឆ្នាំ២០១៨ កសិករចំនួន១០ ០០០នាក់ នៅខេត្តក្រចេះ នឹងអនុវត្តកសិដ្ឋានរបស់ពួកតាមបែបចម្រុះ។

ខ) នៅចុងខែឧសភាឆ្នាំ ២០១៧ កសិករក្រីក្រចំនួន៥០០នាក់ នៅខេត្តកំពង់ឆ្នាំងប្រទេសកម្ពុជានឹងចាប់យកបច្ចេកវិទ្យាទំនើបក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រភេទដីដំណាំស្រូវរដូវប្រាំង។

គ) នៅចុងឆ្នាំ២០១៧ កសិករក្រុមគោលដៅភាគច្រើននឹងប្រើជីសរីរាង្គក្នុងសួរដំណាំរបស់ពួកគេ។

# ២. រៀបចំព្រាងឯកសារផ្សព្វផ្សាយ

ឈរលើលទ្ធផលវិភាគខាងលើ នូវគោលគំនិតទស្សនទានជាក់លាក់និងច្បាស់លាស់នឹងទទួលបាន ហើយនឹងជាជំនួយដ៏សំខាន់ក្នុងការរៀបចំគ្រោងសាច់រឿង ការជ្រើសរើសប្រភេទឯកសារផ្សព្វផ្សាយ ខ្លឹមសារស្នូល កំណត់លំហូរពត៌មាន និងធ្វើឲ្យឯកសារផ្សព្វផ្សាយមានការទាក់ទាញច្រើន។

## ២-១ បង្កើតសាច់រឿង

ចំពោះការបង្កើតសាច់រឿងល្អគឺចាំបាច់អនុវត្តសកម្មភាពដូចខាងក្រោម៖

- បង្កើតចំណងជើង
- បង្កើតសាច់រឿងនិង
- ផ្ទៀងផ្ទាត់សាច់រឿង

**ក)បង្កើតចំណងជើង**

ចំណងជើងសមស្របគួរដកស្រង់ចេញពីកម្មវត្ថុដែលបានកំណត់រួចហើយចំណងជើងល្អគួរតែឆ្លើយតបទៅនឹងតម្រូវការអាទិភាពពិតប្រាកដនិងចំណាប់អារម្មណ៍របស់កសិករ ព្រមទាំងគោលនយោបាយផ្សព្វផ្សាយកសិកម្ម។ ខាងក្រោមជាឧទាហរណ៍នៃចំណងជើងដែលសមស្រប៖

- កសិដ្ឋានចម្រុះ និងផលិតភាព
- បច្ចេកវិទ្យាទំនើបអនុវត្តលើប្រភេទដីស្រែស្រូវប្រាំង
- សួនដំណាំសរីរាង្គ
- អនុវត្តកសិកម្មបែបទំនើបនិងទទួលផលល្អ។

<u>គួរចងចាំថា</u> ចំណងជើងឯកសារគួរសរសេរឲ្យខ្លីនិងនៅផ្នែកខាងលើនៃទំព័រ។

**ខ)បង្កើតសាច់រឿង**

ការបង្កើតសាច់រឿងគឺមានសារៈសំខាន់ណាស់ដែលជាការទាក់ទាញដល់អ្នកអានហេតុដូចនេះ ការសរសេរសាច់រឿងគួរតែផ្តោតតាមការណែនាំដូចខាងក្រោម៖

- រៀបរាប់ពីគុណសម្បត្តិដែលទាក់ទាញដល់កសិករ (មានន័យថាលទ្ធផលជាវិជ្ជមាន)
- រៀបរាប់ពីកត្តាជំរុញលើកទឹកចិត្តដល់កសិករបំផុត (មានន័យថាមូលហេតុដែលចាំបាច់អនុវត្ត)
- រៀបរាប់ពីសកម្មភាពនិងនិតិវិធីដែលកសិករត្រូវអនុវត្តដើម្បីទទួលផលច្រើន។

មើលរូបភាពទី៣បង្ហាញជាឧទាហរណ៍ក្នុងការបង្កើតប្លង់សាច់រឿង។

ចំណងជើង(Topic)→ឱ្យខ្លី និងងាយស្រួលចងចាំ ឧទាហរណ៍

- សួនដំណាំដីសរីរាង្គ
- សួនដំណាំនៅផ្ទះរបស់អ្នក

លទ្ធផល(Effect)→ អ្វីជាគុណសម្បត្តិនៃបច្ចេកវិទ្យាដែលមានការទាក់ទាញច្រើនបំផុត? ឧទាហរណ៍

- កាត់បន្ថយចំណាយក្នុងការទិញដីគីមី
- អាចសម្រប និងធន់នឹងជម្ងឺ និងអាកាសធាតុ

មូលហេតុ(Reason)→ អ្វីដែលលើកទឹកចិត្តដល់កសិករ? ឧទាហរណ៍

- បង្កើនផលិតផល
- ថែរក្សាគុណភាព និងរចនាសម្ព័ន្ធដី
- ផ្តល់នូវបរិយាកាសល្អ

សកម្មភាព(Actions)→ តើសកម្មភាពអ្វីដែលត្រូវការអនុវត្តន៍បច្ចេកវិទ្យាថ្មី? ឧទាហរណ៍

- ការប្រើដីកំប៉ុស្តិ៍នៅក្នុងសួនដំណាំនៅដំណាក់កាលបំប៉នចំនួនxxគីឡូក្រាម ក្នុងដំណាំxxម៉ែត្រការ៉េ។

**គ)ផ្ទៀងផ្ទាត់សាច់រឿង**

ពេលដែលអ្នកពេញចិត្តខ្លឹមសារសាច់រឿងហើយ បន្ទាប់គួរផ្ទៀងផ្ទាត់សាច់រឿងឡើងវិញដើម្បីធានាថាៈ

1) ខ្លឹមសារក្នុងសាច់រឿងឆ្លើយតបនឹងបញ្ហារបស់កសិករពិសេសស្ត្រី។
2) ខ្លឹមសារក្នុងសាច់រឿងផ្តល់ព័ត៌មានគ្រប់គ្រាន់និងមានភាពលម្អិតល្មមគ្រប់គ្រាន់តាមតម្រូវការរបស់កសិករ ជាពិសេសស្ត្រី។
3) ខ្លឹមសារក្នុងសាច់រឿងបង្ហាញពីកសិកម្មបែបវាងវៃ(SMART)និងធន់នឹងបម្រែបម្រួលអាកាសធាតុ។ល។

ផ្ទុយមកវិញ បើសាច់រឿងនោះមានការពេញចិត្តតិចតួច គួរកំណត់ចំណងជើងដទៃផ្សេងទៀត ហើយអនុវត្តទៅតាមដំណើរការដូចដែលបានរៀបរាប់ខាងលើឡើងវិញ។

**គន្លឹះចងចាំ**

- ☐ សរសេរចំណងជើងនៅផ្នែកខាងលើនៃទំព័រក្រដាស
- ☐ ចំណងជើងត្រូវសរសេរឱ្យខ្លី និងងាយស្រួលយល់ និងមានការទាក់ទាញ
- ☐ សរសេរជាចំណុចៗ ដើម្បីជៀសវាងសរសេរ និងរៀបរាប់វែងពេក
- ☐ រចនាសម្ព័ន្ធខ្លឹមសារត្រូវតែតាមលំដាប់លំដោយ មានន័យថាមូលហេតុគាំទ្រខ្លឹមសារលទ្ធផល ហើយសកម្មភាពផ្តល់វិភាគទានដល់លទ្ធផល
- ☐ ប្រើពាក្យពេចន៍ដកស្រង់ចេញពីឯកសារដែលមានស្រាប់បើអាចទៅរួចជាជាងគិតនូវពាក្យពេចន៍ និងខ្លឹមសារថ្មី
- ☐ ទទួលពត៌មានបច្ចុប្បន្នភាព និងពីគេហទំព័រនានា។

## ២-២ ជ្រើសរើសប្រភេទឯកសារផ្សព្វផ្សាយឱ្យសមស្រប

ប្រភេទឯកសារផ្សព្វផ្សាយដែលប្រើប្រាស់ជាទូទៅនៅប្រទេសកម្ពុជារួមមានៈដូចជាខិត្តប័ណ្ណ កូនសៀវភៅ ផ្ទាំងរូបភាព និងវីដេអូ ។ល។ ដូចនេះមុននឹងជ្រើសយកប្រភេទឯកសារផ្សព្វផ្សាយមួយណា គួរចាំបាច់សួរសំណួរដូចខាងក្រោមៈ

- ☐ តើវាជាទូទៅប្រើប្រាស់នៅតំបន់គោលដៅដែរឬទេ?
- ☐ តើវាស្របទៅនឹងក្រុមគោលដៅនិងកម្មវិធីដែរឬទេ?
- ☐ តើចង់បញ្ជូនខ្លឹមសារទៅក្រុមណាជាក់លាក់?
- ☐ តើការចំណាយផលិតឯកសារអាចទៅរួចដែរឬទេ?
- ☐ តើត្រូវការពេលប៉ុន្មានដើម្បីផលិតឯកសារប្រភេទនេះ?

ខិតប័ណ្ណ គឺជាប្រភេទបោះពុម្ពលើក្រដាសខ្នាតតូច អាចបត់ ឬក៏មិនអាចបត់បាន ហើយជាការផ្សព្វផ្សាយ ឬផ្តល់ព័ត៌មានដោយគ្មានយកកម្រៃ។

កូនសៀវភៅ គឺជាសៀវភៅតូចមួយ ដែលមានរូបភាព និងអត្ថបទពត៌មានដែលនិយាយពីផលិតផល ឬសេវាកម្មនានា។






| ខិតប័ណ្ណ/កូនសៀវភៅ(មានទំហំ A4 អាចបត់ជាពីរនៅចំណុចកណ្តាល បោះពុម្ពសងខាង ហើយមានប្រមាណពី ៨-១២ទំព័រ) | |
|---|---|
| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| – ងាយស្រួលផលិត<br>– ចំណាយតិច<br>– ងាយចែកចាយ<br>– អាចយកទៅតាមខ្លួន និងរំលឹកឡើងវិញ<br>– មានពត៌មានច្រើនជាងនៅសៀវភៅស្តើង (brochure) | – មានការលំបាកបន្តិចក្នុងការអនុវត្ត<br>– មានពត៌មានតិច ករណីយកមកបង្រៀន<br>– សម្រាប់តែអ្នកចេះអានអក្សរ |

ផ្ទាំងរូបភាព(Poster) គឺជាផ្ទាំងក្រដាសធំដែលមានរូបភាព ឬរូបថត ឬសញ្ញាផ្សេងៗដែលអាចបិទឬចុចនៅជញ្ជាំង ឬក្តារខៀនបាន ហើយជាធម្មតាគឺសម្រាប់តាំង ឬដើម្បីផ្សព្វផ្សាយ(ឯកសារយោងៈវចនានុក្រមខេមប្រីច)។



| ផ្ទាំងក្រដាស(មានទំហំA3 ឬA2) | |
|---|---|
| គុណសម្បត្តិ | គុណវិបត្តិ |
| – ទស្សនិកជនច្រើននាក់អាចទទួលបាន<br>– ចំណាយតិច<br>– ងាយចែកចាយ<br>– សមស្របសម្រាប់អ្នកមិនចេះអក្សរ | – មានពត៌មានតិច<br>– តម្រូវការអ្នកមានជំនាញខាងក្រាហ្វិក បើមិនដូច្នេះ វានឹងប្រាប់អ្នកមើលនូវរឿងរ៉ាវផ្សេង។ |

<u>គន្លឹះសំខាន់ក្នុងការផលិតខិតប័ណ្ណ កូនសៀវភៅ និងផ្ទាំងរូបភាព</u>

- ☐ ចំណងជើងគួរមានសេចក្តីសន្និដ្ឋានរួមនៃការអង្កេតជាជាងដំណើរការនៃការផលិត។
- ☐ ចំណងជើងគួរមានឈ្មោះអ្នកនិពន្ធ និងអ្នកផ្តល់វិភាគទានឯទៀត
- ☐ ពាក្យពេចន៍គួរសរសេរឱ្យពេញ ជៀសវាងអក្សរកាត់
- ☐ ពាក្យពេចន៍សរសេរពីឆ្វេងទៅស្តាំ
- ☐ អត្ថបទ តារាង ក្រាភិចគួរតែរៀបឱ្យស៊ីចង្វាក់គ្នា
- ☐ អត្ថបទគួរមានអក្សរធំ និងតូចហើយឲ្យច្បាស់និងងាយស្រួលអាន
- ☐ អត្ថបទមួយជួរគួរឱ្យមានប្រមាណ ១០-១២ពាក្យ
- ☐ គួរប្រើពណ៌ស្រាលតាមបែបធម្មជាតិនិងមិនឲ្យដិតខ្លាំងពេកទេ
- ☐ គំនូសបន្ទាត់គួរស្តើងស្រាលៗ។

<u>វីដេអូ</u> ជាផ្នែកសំខាន់នៃដំណើរការបង្កើតរូបភាពដែលបង្ហាញនូវទិដ្ឋភាពពីលើចុះក្រោម ថតចំសកម្មភាព មានកិច្ចសន្ទនាជាក់លាក់ជាមួយនឹងសកម្មភាព។ ទំព័រនីមួយៗនៃសំណេរតំណាងឱ្យប្រហែល១នាទីនៃផ្ទាំងរូបភាព ហើយសំណេរល្អត្រូវតែខ្លី ច្បាស់និងជាក់លាក់។ គួរចងចាំថា អ្នកសំណេរមានចំណេះដឹងអំពីបច្ចេកទេសកសិកម្ម តែក្រុមហ៊ុនថតវីដីអូវិញប្រហែលជាគ្មាន តែក្រុមហ៊ុនអាចមានជំនាញផលិតវីដេអូឱ្យមានការទាក់ទាញដល់កសិករបាន។ ដូចនេះពួកគេអាចជ្រើសរើសសំលេងនិងថតរូបភាពឱ្យសមស្របនឹងអត្ថបទនិងខ្លឹមសារ។ ហេតុដូចនេះ អ្នកសំណេរគួរតែ៖

- ☐ ជ្រើសរើសខ្លឹមសារដោយយកចិត្តទុកដាក់ (មានន័យថា ជ្រើសខ្លឹមសារអត្ថបទពី១-៣រួចផ្តោតលើចំណុចសំខាន់នៃគំនិតទាំងនោះ)។
- ☐ ពេលសរសេរពង្រៀងរួច ចូរអានសំណេរឱ្យខ្លាំង និងកត់ត្រាតើត្រូវការពេលវេលាប៉ុន្មាន? កត្តានេះអាចជួយកំណត់បានចំនុចខ្វះខាត និងឃ្លាប្រយោគប្លែក។ បើវីដេអូមានប្រមាណរយៈពេល១នាទី នោះនឹងត្រូវការចំណាយពេលវេលា២នាទីក្នុងការអាន។ ដូចនេះត្រូវបង្រួមសំណេរឲ្យស្របនឹងពេលវេលានោះ។
- ☐ ធ្វើតេស្តសំណេរវីដេអូដែលបង្ហាញក្នុងរូបភាពទី៤ ជាឧទាហរណ៍។

| ចំណងជើងគម្រោង: វគ្គបណ្ដុះបណ្ដាលស្ដីពីរបៀបផលិតឯកសារផ្សព្វផ្សាយរបស់ASPIRE | | |
|---|---|---|
| ថ្ងៃ-ខែ-ឆ្នាំ: ............../................./................ | | |
| ស្លតលេខ | វីដេអូ-រូបភាព | អត្ថបទសំណោរ |
| ស្លត1 | តើរូបភាពអ្វីដែលអ្នកចង់បង្ហាញ? | រៀបចំអត្ថបទសរសេរយោងតាមរូបភាពនៃស្លតនោះ |
| ស្លត2 | – ផ្ដល់ចំណីសត្វមាន់<br>– ទិដ្ឋភាពវាលស្រែពណ៌មាស<br>– កសិករកំពង់ដើរតាមវាលស្រែ<br>– កសិករឈរនៅក្នុងវាលស្រែ<br>– បូមទឹកដាក់ស្រែ<br>– សត្វមាន់កំពង់រត់ប្រសាច | |
| ស្លត3 | | |
| ស្លត4 | | |
| ស្លត5 | | |

*រូបភាព ៤ រូបភាពសំណោរវីដេអូ*

គួរកត់សំគាល់ថា សំណោរវីដេអូគួររៀបតាមលំដាប់លំដោយនិងតាមប្រធានបទ ហើយអាចកែសម្រួលគ្រប់ស្លតបាននិង គួរមានព័ត៌មានដែលអាចមើលឃើញនៅក្នុងវីដេអូ។ អ្នកថតរូបឬរូបថតដែលជ្រើសរើសគួរចេញពីទីតាំង ជ្រុងនិងចំងាយខុសគ្នា ព្រោះប្រភេទរូបភាពនីមួយៗមានគោលបំណងនិងឆ្លើយតបនឹងអត្ថបទនីមួយៗ។ជំហានទី៦ខាងក្រោមនឹងបកស្រាយពីរការជ្រើសរើសរូបភាពឲ្យមានការទាក់ទាញ។

| វីដេអូ(រយៈពេលក្នុងសេវាផ្សព្វផ្សាយ គឺពី ៥-២០នាទី | |
|---|---|
| គុណសម្បត្តិ | គុណវិបត្តិ |
| – ផ្ដល់ពត៌មានជាក់ស្ដែងច្រើន<br>– ងាយស្រួលយល់<br>– ការអប់រំតាមបែបទស្សនា<br>– សមស្របសម្រាប់អ្នកមិនចេះអក្សរ<br>– ជួយផ្ដល់រូបភាព និងភាពសប្បាយដល់អ្នកទស្សនា<br>– បង្កើនជំនាញពីសង្គម | – តម្លៃថ្លៃ<br>– តម្រូវការឧបករណ៍ និងបច្ចេកវិទ្យាស្មុគស្មាញក្នុងការថត និងចាត់ចែង<br>– តម្រូវការផលិតករមានជំនាញផលិតវីដេអូ និងសរសេរអត្ថបទ<br>– ត្រូវការពេលច្រើនក្នុងកិច្ចប្រជុំជាមួយផលិតករ និងផលិតកម្មវីដេអូ<br>– បើវីដេអូមានព័ត៌មានច្រើន និងរយៈពេលវែង ពួកអ្នកទស្សនានឹងពិបាកយល់។ |

<u>គន្លឹះសំខាន់នៅពេលសរសេរអត្ថបទវីដេអូ</u>

☐ ខ្លឹមសារគួរឲ្យខ្លី និងជាក់លាក់សម្រាប់វីដេអូស្លតរយៈពេល១នាទី

- ខ្លឹមសារកាន់តែច្បាស់ បើសិនមានស្គ្រីបវីដេអូខ្លីច្រើន
- ជៀសវាងផ្តល់ពត៌មានច្រើនលើសលុប
- ប្រើតួសំណេរអក្សរធំ និងងាយស្រួលអាន
- ប្រើពាក្យខ្លី ពិសេសពេលនិយាយ
- រក្សាសំនៀងជាលក្ខណៈសន្ទនា និងប្រាកដថាវាសមស្របនឹងបុគ្គលិកលក្ខណៈរបស់អ្នកអាន
- សរសេរអត្ថបទផ្សារភ្ជាប់ទៅនឹងរូបភាព ដ្យាក្រាម ក្រាភិច ឬតាមធម្មជាតិដែលធ្វើឱ្យវីដេអូមានការចាប់អារម្មណ៍ និងផ្តល់ភាពរីករាយដល់ការទស្សនា
- ប្រើពាក្យខ្ញុំ អ្នក ពីអតីតកាល និងបច្ចុប្បន្នកាលជាអចិន្ត្រៃយ៍
- រាល់វីដេអូនីមួយៗ គួរមានសេចក្តីផ្តើម និងបញ្ចប់
- រយៈពេលវីដេអូ:

  ក) ប្រភេទវីដេអូ មានរយៈពេលខ្លី គឺប្រមាណ៤៥វិនាទី

  ខ) ប្រភេទវីដេអូមានរយៈពេលមធ្យម គឺប្រមាណ១នាទី

  គ) ប្រភេទវីដេអូខ្នាតវែងមានរយៈពេល គឺវាង ២-៥នាទី

គេហទំព័រ គឺជាប្រភេទអត្ថបទដែលមានខ្លឹមសារបង្ហាញអាចមើលឃើញនិងមានសំលេង ហើយវាជាផ្នែកមួយនៃបទពិសោធន៍របស់អ្នកដែលប្រើគេហទំព័រ។ វាអាចជាអត្ថបទ រូបភាព សំលេង វីដេអូ និង រូបជីវចល(ឯកសារយោង https://en.wikipedia.org/wiki/Web_content)។

យោងតាមការស្រាវជ្រាវជាច្រើន អ្នកប្រើគេហទំព័រភាគភាគច្រើនមិនមានទម្លាប់អានរាល់ខ្លឹមសារទាំងអស់នោះទេ តែគ្រាន់តែអានពាក្យខ្លះៗប៉ុណ្ណោះ។ ជាក់ស្តែងការអានលើអេក្រង់ជាទូទៅមានការលំបាកជាងអាននៅលើក្រដាស។ ហេតុដូចនេះ អ្នកសរសេរគេហទំព័រគួរព្យាយាមឱ្យអស់ពីលទ្ធភាពដោយធ្វើយ៉ាងណាឱ្យខ្លឹមសារនៅក្នុងគេហទំព័រមានការទាក់ទាញច្រើនដែលអាចទៅរួចដល់អ្នកអាន។ កត្តានេះនាំឱ្យអ្នកអានអាចមានការយកចិត្តទុកដាក់ ហើយបន្ទាប់មកពួកគេអាចក្លាយជាអ្នកសរសេរខ្លឹមសារនៅក្នុងគេហទំព័រជាជាងអ្នកផលិត។ ដូចនេះការសរសេរនៅគេហទំព័រ គួរកុំឱ្យមានខ្លឹមសារច្រើននិងវែងពេក តែឱ្យសមស្រប និងជាទម្រង់ត្រឹមត្រូវដែលបង្កឱ្យងាយស្រួលអាន។

មុនសរសេរខ្លឹមសារនៅគេហទំព័រ គួរមានសំណួរមួយចំនួនដូចជា៖

- ហេតុអ្វីបានជាពួកគេអានអត្ថបទនៅគេហទំព័រ?
- តើពួកគេអានព័ត៌មាននៅគេហទំព័រតាមរបៀបណា?
- ហេតុអ្វីបានជាអ្នកសរសេរអត្ថបទនៅគេហទំព័រ? និង
- តើជំនាញសរសេរល្អៗអ្វីខ្លះដែលអ្នកសរសេរគួរដឹង និងមាន?




ក្បួនខ្នាតក្នុងការសរសេរអត្ថបទនៅគេហទំព័រ:

- ចំណងជើងគួរមានពាក្យប្រមាណពី៨-១០ ឬតិចជាងនេះ
- ឃ្លាប្រយោគគួរមានប្រមាណពី១៥-២០ពាក្យ
- មួយកថាខ័ណ្ឌគួរមានប្រមាណ៤០-៧០ពាក្យ
- មួយទំព័រគួរមានប្រមាណ៥០០ ពាក្យ ឬតិចជាងនេះ

គេហទំព័រល្អគួរតែសរសេរ:

- ព្យាយាមផ្តោតយកចិត្តទុកដាក់ដល់អ្នកអានដោយប្រើ ២-៣ពាក្យដំបូង
- ចាប់ផ្តើមដោយសេចក្តីសន្និដ្ឋាន បន្ទាប់មកផ្តល់ជាលម្អិត
- ផ្តល់គោលគំនិតមួយនៅក្នុងមួយកថាខ័ណ្ឌ
- ឲ្យច្បាស់ និងជាក់លាក់
- ប្រើប្រយោគធម្មតាៗ
- ឲ្យឆ្លុះបញ្ចាំងចំណុចគោលផ្ទាល់តែម្តង
- ចំណងជើងរងឱ្យមានអត្ថន័យ
- ចំណុចរាយនូវបញ្ហា
- រំលេចពាក្យគន្លឹះៗ

ផ្ទុយមកវិញ កុំសរសេរខ្លឹមសារនៅគេហទំព័រដូចខាងក្រោម៖

- ស្វាគមន៍ទស្សនិកជន និងពន្យល់អ្វីទៅជាគេហទំព័រនៅក្នុងគេហទំព័រ
- សរសេរខ្លឹមសារបេសកកម្មនៅទំព័រដំបូង
- សរសេររាល់ខ្លឹមសារដែលអ្នកមាន

- ☐ ប្រើសំណេរជារបៀបលើកដំកើន និងតាមទំហំទីផ្សារ
- ☐ ចាត់ចែង និងសរសេរខ្លឹមសារស្តីពីស្ថាប័នរបស់ខ្លួន
- ☐ ឯកសារជាទម្រង់ PDF បើមិនចាំបាច់។

## ២-៣ ជ្រើសរើសភាសាឱ្យសមស្រប

ការជ្រើសរើសភាសាឲ្យសមស្របគឺមានការលំបាកតែមានសារៈសំខាន់ណាស់ក្នុងការផលិតឯកសារផ្សព្វផ្សាយ ហើយចំណុចខាងក្រោមគួរយកចិត្តទុកដាក់រួមមាន៖

- ☐ ឆ្លុះបញ្ចាំងនឹងគោលបំណងកម្មវិធី និង ក្រុមគោលដៅ
- ☐ ប្រើភាសាក្នុងស្រុក បើមានភាសាបច្ចេកទេស និងវិទ្យាសាស្ត្រ គួរបកស្រាយនិងពន្យល់ជាភាសាក្នុងស្រុក។ បើមានពាក្យបច្ចេកទេសពិបាកយល់គួរពន្យល់ជាឃ្លាប្រយោគបន្ថែម ដោយរូបគំនូសក្រាភិចជាដើម។ល។
- ☐ យកចិត្តទុដាក់លើក្រុមគោលដៅជាពិសេសស្ត្រី
- ☐ ទាត់ចោលសមាជិកឬក្រុមណាមួយនៅក្នុងសហគមន៍( ឧ. គ្រួសារអ្នកមាន និងអ្នកក្រ។ល។)
- ☐ ប្រើពាក្យ និងកិរិយាស័ព្ទសាមញ្ញ និងធម្មតា ឧទាហរណ៍

| ជំនួសដោយពាក្យ/កិរិយាស័ព្ទខាងក្រោម | គួរប្រើ |
|---|---|
| – ទទួលបាន( obtain ) | ទទួល( Get ) |
| – អាទិភាពមុន( Prior to ) | មុន( Before ) |
| – ជាវ( Perchase ) | ទិញដូរ( Buy ) |
| – សំណើរ( Request ) | ស្នើរ( Ask for ) |
| – បម្រើបម្រាស់( Utilise ) | ប្រើ( Use ) |
| – ដែលដឹងឮ( Cognizant ) | ស្គាល់ដឹង( Know ) |
| – សម្របសម្រួល( Facilitate ) | ជួយ( help ) |
| – ជាបន្តបន្ទាប់( Subsequent ) | បន្ទាប់មក( Next ) |

កត់សំគាល់ថាពាក្យ និងកិរិយាស័ព្ទដែលនិយមប្រើប្រាស់ច្រើន គឺមាននៅក្នុងសៀវភៅបណ្តុះបណ្តាលរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្មស្តីពីជំនាញសម្របសម្រួល និងប្រាស្រ័យទាក់ទងដែលរៀបរៀងដោយបណ្ឌិត ម៉ាក់ សឿន និង សាយ តុម នាឆ្នាំ ២០១៥។

ចំណុចខាងក្រោមគួរពិចារណាបន្ថែម ពេលជ្រើសរើសសារឱ្យបានសមស្រប៖

- ☐ ផ្តល់ផលដល់ក្រុមគោលដៅ( ឧ. ចំណេញច្រើន តម្រូវការមនុស្សភាគច្រើន មានសុវត្ថិភាពល្អ និងហានិភ័យទាប។ល។)។
- ☐ រំលេចនូវហានិភ័យ និងពន្យល់ពីបញ្ហានៅពេលអ្នកណាម្នាក់មិនអាចទទួលយកបច្ចេកវិទ្យាទំនើប

- ◻ សារគួរនិយាយចំៗ ច្បាស់លាស់ (កុំនិយាយច្រើនពេក)
- ◻ នឹងវប្បធម៌ និងការចេះដឹងរបស់ក្រុមគោលដៅ
- ◻ តាមលំដាប់លំដោយ
- ◻ ងាយស្រួលអាន និងយល់
- ◻ ស្រាយបំភ្លឺដោយរូបភាព និងងាយស្រួលយល់ដោយក្រុមគោលដៅ
- ◻ សរសេរតាមមធ្យោបាយមួយដែលជំរុញឱ្យពួកគេធ្វើសកម្មភាព
- ◻ សិក្សាថាតើកសិករអាចទទួលព័ត៌មានឱ្យបានច្បាស់និងបានច្រើនតាមរបៀបណា?

## ២-៤ រៀបចំគំនូសប្លង់ព្រាងឯកសារ

ទោះបីបានប្រើភាសាបានច្បាស់និងសមស្របក៏ដោយ តែការផលិតឯកសារឱ្យមានការទាក់ទាញដល់អ្នកអានក៏ចាំបាច់ផងដែរ។ ហេតុដូចនេះការរៀបចំគំនូសប្លង់ព្រាងឯកសារគួរអនុវត្តជា៤ជំហាន:

- ◻ រៀបចំពង្រៀងគំនូសប្លង់ឯកសារផ្សព្វផ្សាយដោយវាយអក្សរ ប្រយោគ ឬដាក់រូបថត ឬក្រាភិច។
- ◻ សរសេររាល់ចំណុច និងរូបភាព ឬគំនូសគូរទាំងអស់ដែលចង់បញ្ចូលទៅក្នុងឯកសារ
- ◻ ចាត់ចែងតាមលំដាប់លំដោយ ដោយកំណត់នូវចំនួនអត្ថបទ រូបភាព គំនូសគូរ ទំហំ តុល្យភាព ហើយដាក់ឱ្យខុសៗគ្នា។
- ◻ រៀបចំគំនូសប្លង់ឱ្យងាយស្រួលយល់ព្រមទាំងមានការទាក់ទាញច្រើន។

(ឯកសារយោង JICA/EIAR FRG II Project 2014, គោលការណ៍ណែនាំក្នុងការផលិតឯកសារផ្សព្វផ្សាយ)។

## ២-៥ រៀបចំឯកសារផ្តោតលើលំហូរព័ត៌មាន

បើចង់បានសារមួយមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងបញ្ជូនទៅដល់អ្នកអានលំហូរព័ត៌មានគួរធ្វើមិនដឹងមិនឮឱ្យសោះ។ ភ្នែករបស់មនុស្សមានលក្ខណៈពិសេស ហើយពួកគេអានអត្ថបទតាមរបៀបផ្សេងៗពីគ្នា។ ឧទាហរណ៍ ប្រជាជនកម្ពុជាអានអត្ថបទពីស្តាំទៅឆ្វេង រួចពីលើចុះក្រោមដូចអក្សរ"Z" ផ្ទុយមកវិញប្រជាជនចិនអានពីលើចុះក្រោមរាងដូចអក្សរ"N"។ មើលរូបភាពទី៥ នៃលំហូរព័ត៌មានសំខាន់ពីរជាមូលដ្ឋានខាងក្រោម។

រាងZ(សម្រាប់ប្រជាជនកម្ពុជា)



រាងN(សម្រាប់ប្រជាជនចិន)



រូបភាព ៥ ប្រភេទនៃលំហូរព័ត៌មាន

មានលំហូរពត៌មានមួយចំនួនទៀតដែរ (មើលរូបភាពទី៦)ដែលត្រូវយកចិត្តទុកដាក់ផងដែរដើម្បីឱ្យឯកសារផ្សព្វផ្សាយកាន់តែមានការទាក់ទាញ និងងាយស្រួលអានដែលបង្កឲ្យអ្នកអានទទួលយកសារសំខាន់ៗបាន។ រូបភាពទី៧ បង្ហាញពីពត៌មានផ្សេងៗដែលអ្នកផលិតឯកសារត្រូវប្រើឱ្យបានត្រឹមត្រូវ លឿន និងរហ័ស ដោយយោងទៅតាមគោលបំណងនៃព័ត៌មានចង់ផ្សព្វផ្សាយ។

| | |
|---|---|
| លំហូរពត៌មានបែបផ្តេក(បង្ហាញពីទំនាក់ទំនងផ្សារភ្ជាប់គ្នាពីមួយទៅមួយនិងតាមលំដាប់លំដោយ)   | លំហូរពត៌មានបែបបញ្ឈរ(បង្ហាញពីទំនាក់ទំនងបែបឋានុក្រម)   |
| លំហូរពត៌មានបែបរង្វង់មូល(បង្ហាញពីដំណើរការជាបន្តបន្ទាប់)   | លំហូរពត៌មានបែបគងលើគ្នា(បង្ហាញពីបញ្ហាគងលើគ្នារវាងគ្នា)  |

| លំហូរពត៌មានបែបពីរ៉ាមីត(បង្ហាញពីមូលដ្ឋានគ្រឹះនៃទំនាក់ទំនង) | លំហូរពត៌មានពីគោលដៅ(បង្ហាញជំហានៗដើម្បីទទួលគោលដៅមួយ) |
| --- | --- |
|   |  |

រូបភាព ៦ ប្រភេទនៃលំហូរពត៌មានផ្សេងៗទៀត

## ២-៦ រៀបចំឯកសារឱ្យទាក់ទាញខ្លាំង

ក្រៅពីការយកចិត្តទុកដាក់លើសារពត៌មាន ភាសាសមរម្យ និងលំហូរពត៌មាន អ្នកផលិតឯកសារជាធម្មតានឹងប្រឈមបញ្ហាផ្សេងទៀតដូចជារបៀបបង្ហាញពត៌មានឱ្យមានការទាក់ទាញខ្លាំង។ ពត៌មានខ្លះគឺសមស្របបង្ហាញជាពាក្យពេចន៍ ក្រាភិច ឬរូបថត។ រូបថត ឬរូបភាពជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការបញ្ជូនសារ បើរូបថត ឬរូបភាពដែលថត និងគូរនោះឆ្លើយតបនឹងខ្លឹមសារសំណេរ។ ផ្ទុយមកវិញ រូបថតដោយថតមិនបានឆ្លើយតបនឹងខ្លឹមសារនោះទេ វានឹងផ្តល់លក្ខណៈអវិជ្ជមាន។

ពេលថត និងជ្រើសរើសរូបថត ចាំបាច់គួរយល់ដឹងថាតើខ្លឹមសារអ្វីដែលចង់ផ្សព្វផ្សាយ(ឧទាហរណ៍ រូបរាងក្រៅរបស់ឯកសារ ទម្រង់ រចនាសម្ព័ន្ធ។ល។)។ ពេលដែលរូបភាពមានលក្ខណៈច្បាស់ហើយ គួរយកចិត្តទុកដាក់បន្ថែមពីបច្ចេកទេសខ្លះក្នុងការថត ដែលជួយបំភ្លឺពីគោលបំណងកាន់តែច្បាស់បន្ថែមទៀត។

រូបភាពខាងក្រោមផ្តល់នូវគន្លឹះដ៏សំខាន់ពេលជ្រើសរើសរូបគំនូរ ឬថតរូបសម្រាប់ឯកសារផ្សព្វផ្សាយ(មើលរូបភាពទី៧)។

<u>គន្លឹះចងចាំក្នុងការប្រើគេហទំព័រស្វែងរកពត៌មាន និងរូបភាព</u>

គេហទំព័រជាប្រភពពត៌មានមួយដ៏មានប្រយោជន៍ពេលអ្នកចាប់ផ្តើមផលិតឯកសារផ្សព្វផ្សាយ។ វាមានរបាយការណ៍ ទិន្នន័យ រូបថត និងរូបវិស្សុតកម្មច្រើនណាស់ដែលអាចដកស្រង់ចេញពីគេហទំព័រដោយគ្មានការចំណាយ។ ចូលចងចាំថារាល់ពត៌មានទិន្នន័យ និងរូបភាពទាំងអស់មានកម្មសិទ្ធហេតុដូចនេះពេលប្រើវាត្រូវផ្តល់ឯកសារបង្អែក ឬដកស្រង់ចេញពីប្រភពណា។

<table>
<tr><td colspan="2">ពង្រីករូបភាពឱ្យធំ និងច្បាស់</td></tr>
<tr><td></td><td></td></tr>
<tr><td colspan="2">ត្រួតពិនិត្យពីទិសដៅពន្លឺព្រះអាទិត្យ(ម្លប់) និងផ្ទៃរូបភាព</td></tr>
<tr><td>
</td><td>
</td></tr>
<tr><td colspan="2">ប្រើផ្ទៃរូបភាព និងរូបភាពពិតអាចរំលេចកាន់តែច្បាស់</td></tr>
<tr><td></td><td></td></tr>
<tr><td colspan="2">រៀបរូបភាពយោងទៅតាមតម្រូវការ</td></tr>
<tr><td><br>ជារង្វង់</td><td><br>ការរៀបចំ</td></tr>
</table>

រូបភាព ៧ ការជ្រើសរើសរូបភាព

# ៣. វាយតម្លៃពង្រាងឯកសារ

មានសកម្មភាព២សំខាន់ក្នុងការវាយតម្លៃពង្រាងឯកសារៈ ១)ត្រួតពិនិត្យនិង ២)ធ្វើតេស្ត។ ក្រោយប្រមូលព័ត៌មានរួចហើយ គួរធ្វើការកែលម្អជាបន្តបន្ទាប់ ទោះបីនៅពេលអនុវត្តក៏ដោយ។

## ៣-១ ត្រួតពិនិត្យឯកសារ

មុននឹងបោះពុម្ពឯកសារ ជាការចាំបាច់ត្រួតពិនិត្យតបតាមសំណួបញ្ជីដូចខាងក្រោមថាតើ៖

- ☐ ឯកសារផ្សព្វផ្សាយនេះបានឆ្លើយតបនឹងតម្រូវការរបស់កសិករដែរឬទេ ?
- ☐ ចំណងជើងអត្ថបទមានលក្ខណៈសាមញ្ញ និងច្បាស់ដែរឬទេ ?
- ☐ ប្រភេទឯកសារសមស្របនឹងសារ និងមានទម្រង់បែបបទត្រឹមត្រូវដែរឬទេ ?
- ☐ ភាសា និងពាក្យពេជន៍ដែលប្រើក្នុងអត្ថបទមានលក្ខណៈសាមញ្ញ ភាសាស្រុក និងបង្ហាញពីប្រពៃណីនៃក្រុមគោលដៅដែរឬទេ ?
- ☐ ប្លង់ឯកសារងាយមើល មានលំហូរពត៌មានតាមលំដាប់លំដោយ និងទាក់ទាញដល់ក្រុមគោលដៅដែរឬទេ ?
- ☐ ចំណុចសំខាន់ៗនៃខ្លឹមសារមានលក្ខណៈលំដាប់លំដោយដែរឬទេ ?
- ☐ សារឆ្លុះបញ្ចាំងពីរូបថត/ គំនូសនីមួយៗច្បាស់ និងសមស្របនឹងខ្លឹមសារដែរឬទេ ?
- ☐ គែមទំព័រសមស្របដែរឬទេ ?
- ☐ មានអក្សរខុស និងផ្តាំផ្គងដែរឬទេ ?
- ☐ ឯកសារនេះមានពត៌មានដូចជា១)ឈ្មោះអ្នកនិពន្ធនិងស្ថាប័នរួមទាំងមានអាស័យដ្ឋានទំនាក់ទំនង ២)ឆ្នាំផលិត ៣)ទីកន្លែងផលិត ៤)ស្ថាប័នដែលជាម្ចាស់ឯកសារ ៥) ឈ្មោះអ្នកកែសម្រួល ៦) ឈ្មោះអ្នកគូសក្រាភិចឬ)ឈ្មោះអ្នកថតរូប និងម្ចាស់ជំនួយ។ល។

## ៣-២ តេស្តឯកសារ

វាជាសកម្មភាពមួយដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍន៍ឯកសារផ្សព្វផ្សាយឲ្យមានប្រសិទ្ធិភាព។ សំណួរធំ ២គួរសួរនៅពេលធ្វើតេស្ត៖

1. តើនរណាជាក្រុមគោលដៅក្នុងការធ្វើតេស្តនេះ? ដូចជាបុគ្គលិកជំនាញ និង/ឬក្រុមគោលដៅ ក្រុមមនុស្សដទៃទៀតដែលពាក់ព័ន្ធ។
2. តើធ្វើតេស្តលើកត្តាអ្វី?មានកត្តា៥យ៉ាងគួរពិចារណាក្នុងពេលធ្វើតេស្តដែលមានដូចខាងក្រោម៖

- ☐ តើខ្លឹមសារ និងមធ្យោបាយបង្ហាញព័ត៌មានច្បាស់លាស់ និងមានគោលដៅច្បាស់លាស់ដែរឬទេ ?
- ☐ តើឯកសារផ្សព្វផ្សាយមានការទាក់ទាញដែរឬទេ ?
- ☐ តើសារពត៌មានអាចទទួលយកបានពីក្រុមគោលដៅដែរឬទេ ?
- ☐ តើក្រុមគោលដៅអាចកំណត់ និងរៀបរាប់ពីរូបភាព រូបគំនូស និមិត្តសញ្ញា និងភាសាដែលឆ្លុះបញ្ចាំងពីលក្ខណៈសម្បត្តិរបស់ក្រុមពួកគេបានកម្រិតណា ?
- ☐ តើឯកសារផ្សព្វផ្សាយបង្ហាញពីអន្តរាគមន៍ដល់ការលើកកម្ពស់វិស័យកសិកម្មនៃក្រុមគោលដៅចង់បាន និងអាចអនុវត្តបានកម្រិតណាដែរ ?

សំណួមពរថា រាល់សំណួរគួររៀបចំពេលមុនពេលចុះធ្វើតេស្ត។ វាអាចជួយដល់ការធ្វើសន្ទនារបស់អ្នកសម្ភាសន៍ ជាមួយក្រុមគោលដៅឲ្យបានប្រសើរ។

# ឯកសារយោង


- **Bell, J Hill and S Atallah** (2013): Extension Material Development*: UCDAVIS factsheet.*
- **DM Best Practices**: Writing for the Web
- **GDA/DAE** (2016): Series of Training Documents.
- **Khieu H (2017):** Training Curriculum for Extension Materials Development.
- **JICA/EIAR** (2014): Guideline for Extension Material Development for Researcher.
- **Manish, B** (2014): Developing Learning Resource Material Using Different Media.

- **About Scriptwriting** via www.texas-pictures.com/contents/documents/script_template.doc
- **How to Develop and Produce Simple Learning Materials with Limited Resources at Community Level** via http://www.accu.or.jp/litdbase/pub/dlperson/pdf0106/rpp25.pdf
- **How to Write a Good Script** via http://blogs.techsmith.com/tips-how-tos/how-to-write-a-good-script/http://blogs.techsmith.com/tips-how-tos/how-to-write-a-good-script/
- **IEC Material Production Guidelines** via http://www.kswann.com/IEC%20Production%20Guidelines.pdf
- New Products Development Process via https://nyccto.wordpress.com/2011/06/10/new-product-development-process-building-launching-products-the-right-way/
- **Web Content Writing Tips** via http://contentwritings.com/web-content-writings/
- **Writing and Organizing Content for Web and Writing For Web** via https://www.google.com.kh/search?q=design+notes&biw=1422&bih=629&source=lnms&sa=X&ved=0ahUKEwjFjp-0rqPQAhUBzbwKHc21CJQQ_AUIBSgA&dpr=1.35#q=web+content+writing+ppt
  **Writing Business Message** via http://slideplayer.com/slide/4141850/